ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃអង្គារ ១០រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២២

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងារវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយគណៈប្រតិភូធនាគារវឌ្ឍនៈអាស៊ីចំកាត់ ( ABA )

នាព្រឹកថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២២, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួប និងពិភាក្សាការងារជាមួយគណៈប្រតិភូធនាគារវឌ្ឍនៈអាស៊ីចំកាត់ ហៅកាត់ថាធនាគារ ABA ដែលដឹកនាំដោយលោក Yves Jacquot ប្រធានក្រុមប្រឹក្សាភិបាល របស់ធនាគារ ABA អមដំណើរដោយលោក Madi Akmambet អភិបាលប្រតិបត្តិធនាគារ ABA, លោក Askhat Azhikhanov នាយកប្រតិបត្តិធនាគារ ABA, Dominic Jacques នាយករងផ្នែកអភិវឌ្ឍអន្តរជាតិនៃធនាគារជាតិកាណាដា និង លោកស្រី ជាម រមណីយ នាយិកាទំនាក់ទំនងគូភាគី និងជាប្រធានគ្រប់គ្រងតំបន់ធនាគារ ABA។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅ ដោយបានកោតសរសើរ និងថ្លែងអំណរគុណដល់ធនាគារ ABA ដែលបានចូលរួមយ៉ាងសកម្ម លើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងបានណែនាំប្រជាជនកម្ពុជានូវផលិតផល និងសេវាកម្មឌីជីថលថ្មីៗ ប្រកបដោយនវានុវត្តន៍ សំដៅជំរុញវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាទៅមុខមួយកម្រិតទៀត ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានគូសបញ្ជាក់ពីកិច្ចសហប្រតិបត្តិការវាងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" សេនាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងធនាគារ ABA នាពេលកន្លងមក ដែលបានឆ្លុះបញ្ចាំងតាមរយៈអនុស្សរណៈយោគយល់គ្នារវាងស្ថាប័នទាំងពីរ និង ក្នុងកម្មវិធីផ្សេងៗទៀត ក្នុងក្របខណ្ឌធុរកិច្ចថ្មីបច្ចេកវិទ្យា, បច្ចេកវិទ្យាហិរញ្ញវត្ថុ និងថ្នាលគ្រឹះឌីជីថល។ ឆ្លៀតក្នុងឱកាសនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានស្នើធនាគារ ABA បន្តផ្តល់ការគាំទ្រ និងសហការយ៉ាងជិតស្និទ្ធបន្ថែមទៀត ជាមួយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ក្នុងការចូលរួមគាំទ្រ សហការរៀបចំ អភិវឌ្ឍ និងប្រើប្រាស់ថ្នាលគ្រឹះឌីជីថលកម្ពុជា រួមមាន ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ( CamDX ), ថ្នាល CamDigiKey និង ថ្នាល CamDigiPay ផងដែរ ។

លោក Yves Jacquot ក៏បានថ្លែងអំណរគុណដល់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដែលបានផ្តល់ការអនុញ្ញាតដល់គណៈប្រតិភូធនាគារ ABA ចូលសម្តែងការគួរសម ។ លោកបានបន្ថែមថា ធនាគារ ABA កន្លងមកធ្លាប់បានធ្វើការជាមួយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" រួចមកហើយ និងនៅតែបន្តធ្វើការជាមួយគ្នាបន្តទៀត តបតាមសំណើរបស់

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដែលក្នុងនោះរួមមានទាំងការគាំទ្រជាថវិកា មិនមែនថវិកា និងធនធានមនុស្ស (Mentors), ផ្តួចផ្តើមបង្កើតកម្មវិធីថ្មីសម្រាប់គាំទ្រដល់ធុរកិច្ចថ្មីបច្ចេកវិទ្យា, ផ្តល់នូវបរិស្ថានសាកល្បង PayWay សម្រាប់ធុរកិច្ចថ្មីធ្វើតេស្តសាកល្បង និងអភិវឌ្ឍផលិតផល ឬ សេវាកម្មរបស់ខ្លួន, ចូលរួមប្រើប្រាស់ថ្នាលគ្រឹះឌីជីថលផ្សេងៗរបស់រាជរដ្ឋាភិបាលដែលគាំទ្រដល់វិស័យហិរញ្ញវត្ថុធនាគារ និង អភិវឌ្ឍថ្នាលគ្រឹះឌីជីថលរួមគ្នា។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានថ្លែងអំណរគុណសារជាថ្មីម្តងទៀតដល់ធនាគារ ABA និងសង្ឃឹមយ៉ាងមុតមាំថា ធនាគារនឹងបន្តផ្តល់ការគាំទ្រ និងសហការផ្សេងៗទៀត ជាមួយរាជរដ្ឋាភិបាល សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកម្ពុជា ក្នុងក្របខណ្ឌវិស័យហិរញ្ញវត្ថុធនាគារ។